# ១៧.រឿង បក្សីលៀងអារក្ស

នេះនឹងថ្លាថ្លែងពីរឿងសត្វទាំងឡាយ កើតចលាចលដោយសារសត្វផងគ្នាមានជំងឺ ហើយដើរស្វែងរកមេមត់មកជួយមើល ។

កិរៈ កាលនោះ មានសត្វព្រាបមួយមានទុក្ខដោយឆ្លងទន្លេមិនរួច ម្ល៉ោះហើយព្រាបចេះតែថ្ងូរហ៊ឺះសុំឲ្យគេជួយ ។ ត្រង់នេះហើយដែលនាំឲ្យព្រាប ជាប់យំថ្ងូររហូតដល់សព្វថ្ងៃនេះ ។ព្រាបយំថ្ងូរខ្លាំងយ៉ាង

នេះ ក៏ផ្អើលទៅដល់សត្វដទៃទៀត មកជួយមើលឈូឆរ។ ក្នុងបណ្ដាអ្នកដែលមកជួយនោះ មានសត្វខ្លះក៏ជួយឈឺឆ្អាលតែមានសត្វខ្លះទៀត ត្រឡប់ជាបញ្ឆោះបន្សោកបន់ផ្ដន្ទាឲ្យព្រាបទៅវិញ ហេតុនេះ

បានជាមានសម្រែកសត្វប្លែកៗគ្នា តាមភាសាវា គឺខ្លះស្រែកជួយឈឺឆ្អាល និងខ្លះទៀតស្រែកផ្ដន្ទា ៖

មាន់, ទា, ក្អែក ស្រែកផ្ដន្ទា ៖

- ក្អែកស្រែកថា ៖ " ងាប់ឥឡូវ ! ងាប់ឥឡូវ ! ងាប់ឥឡូវ ! " (ត្រង់នេះហើយបានជាក្អែកនៅជាប់ស្រែកថា ៖ ឡូវ ៗ នៅដល់សព្វថ្ងៃ ។ )
- មាន់ស្រែកថា " ចប ! ចប ! " បានន័យថាឲ្យរកចបមកបម្រុងចាំកប់ខ្មោចព្រាបតែម្ដងទៅ ព្រោះព្រាបនេះ វានឹងស្លាប់ឥឡូវហើយ ។ នេះជាពាក្យបញ្ឆោះ ព្រោះមាន់ចង់ឲ្យព្រាបស្លាប់ចុះ ។
- ទាស្រែកបន្ថែមតាមក្រោយមាន់ថា " កាប់ ! កាប់ ! កាប់ ! " ព្រោះថាបើព្រាបស្លាប់ហើយ មាន់ឲ្យគេរកចបហើយនោះ ត្រូវកាប់ដី កប់វាតែម្ដងទៅ ។

ក្រៅពីសត្វដែលផ្ដន្ទាឲ្យព្រាបស្លាប់ នៅមានសត្វដែលជួយសង្គ្រោះព្រាបច្រើនទៀត ។ នៅពេលនោះសត្វរលកស្រែកថា " រ៉កគ្រូ ! រ៉កគ្រូ ! " តែសត្វដទៃជំនុំគ្នាថា ត្រូវទៅរករូបមេមត់

ឲ្យជួយសង្គ្រោះជីវិតសត្វព្រាបវិញ ប៉ុន្តែរូបមេមត់នោះនៅឆ្ងាយណាស់ ហើយពេលនេះជារដូវវស្សា មានទឹកជោរជន់លិចវាលល្ហល្ហាចផង ។ បើនឹងធ្វើដំណើរទៅ គោងតែរកទូកក្ដារច្រវាចែវទើបបាន

ម្ល៉ោះហើយពួកអ្នកសង្គ្រោះទាំងនោះ ម្នីម្នាស្រែកកកោកកកាករកប្រដាប់ទាំងនេះ លាន់ទ្រហឹង ៖

- អាអូត ស្រែកថា ៖ ទូក ! ទូក ! ទូក !
- មាន់ទឹកស្រែកថា ៖ ច្រវា ! ច្រវា ! ច្រវា ! ។
- ប្រវឹកនិង ស្មោញ នាំគ្នាបាចទឹកចេញពីទូកឮសូរ ខ្ញក់ ! ខ្ញក់ ! រួចហើយគេក៏ចេញទូក ដឹកនាំទាំងព្រាបដែលជាអ្នកជំងឺនោះឆ្ពោះទៅលំនៅមៀមជារូបមេមត់ ។ ទម្រាំទៅដល់ជាពេលពន់ព្រលប់
- សត្វមៀមរូបមេមត់យកសត្វទីទុយជាស្នំ គឺជានិយាយលួងលោមរូបមេមត់ ។

បណ្ដាសត្វដែលមានសម្រែកផ្សេង ៗគ្នា ក៏ប្រជុំគ្នាធ្វើជាវង់ភ្លេង អារក្សមួយវង់ ដើម្បីបញ្ចាន់រូបមេមត់នោះគឺ ៖ សត្វត្លុមធ្វើស្គរ, សារិកាកែវធ្វើទ្រ, ល្វាចេកធ្វើប៉ី ត្រសេះវាយក្រាបនិងទន្សោងជាអ្នកច្រៀង។

លុះនាំគ្នាធ្វើបទភ្លេង បានមួយយប់ហើយ ទីទុយជាស្នំ ចាប់ផ្ដើមសួរឡើងថា ៖ ទីទុយពើតពើង ! កូនយើងជាទេ ? ទីទុយពើតពើង ! កូនយើងជាទេ ?

មៀមដែលជារូបមេមត់ ពុំមានស្តីថាអ្វីសោះ រឹតតែបើកភ្នែកធំឡើង ៗ ។ លុះទីទុយនៅតែសួរដដែល ៗ ពេក ក៏ឆ្លើយតែមួយម៉ាត់ថា ៖ លៀង ! លៀង !

ឮដូចនោះ គ្រលីងគ្រលោងក៏ស្រែកឡើងថា៖ " ជាក៏លៀង មិនជាក៏លៀង ជាក៏លៀង មិនជាក៏លៀង ! ”

លុះចប់ពិធីបញ្ចាន់រូបមេមត់រួចហើយ សត្វទាំងអស់ក៏នាំគ្នាវិលមកកាន់កំពង់ ដើម្បីឆ្លងត្រឡប់មកកន្លែងខ្លួនវិញ ។ មកដល់កំពង់រកទូកពុំឃើញក៏បង្ហូកហៅរកគ្នាក្រែងមានអ្នកណាយកទូកទៅអុំលេង

ស្រាប់តែមានសត្វមួយស្រែកឆ្លើយពីត្រើយម្ខាងមក ថាៈ គូក ! ។ គេក៏នាំគ្នាដាក់ឈ្មោះសត្វនោះថា សត្វគូក ៗ រហូតដល់សព្វថ្ងៃ ។ចំណែកសត្វភ្នែកដែលជាសត្វផ្តន្ទាឲ្យព្រាបស្លាប់ តែត្រឡប់ជាមិន

ស្លាប់វិញ ដោយបានទីទុយ, មៀម, គូកជួយយកអាសានោះ ក៏ប្រកាន់ស្អប់សត្វទាំងនេះតែកាលណាឃើញសត្វទាំងនេះហើយ តែងតែព្រួតគ្នាដេញចឹកព្យាបាទ ជាប់រហូតដល់សព្វថ្ងៃនេះ ។